**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤៩ . អនក្រ . បក

# អនុក្រឹត្យ

**ស្តីពី**

**ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.៩០០ ហិកតា**

**ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកអណ្តូងមាស ខេត្តរតនគិរី**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៨ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា១: –**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ១.៩០០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំម៉ាលិក និង ឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនគិរី ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ដូចមានក្នុងផែនទី និង និយាមកាលេខ ១៣០៨/១០ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០ របស់សាលាខេត្តរតនគិរី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២: –**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្រប តាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

**មាត្រា៣: –**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ –**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទី: ចំណុចគោលព្រំដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជាំងលី (អ៊ិនវេសមេន) ខូអិលធីឌី ស្ថិតនៅក្នុងស្រុកអណ្តូងមាស ខេត្តរតនគិរី




| ចំណុចដែលក្រុមការងារពិនិត្យឃើញ | | | |
|---|---|---|---|
| N | X | Y | ពន្យល់ |
| 1 | 748574 | 1527688 | ចំការស្វាយចន្ទី |
| 2 | 748512 | 1527550 | ចំការស្វាយចន្ទី |
| 3 | 749347 | 1527354 | ដីភូមិ |
| 4 | 749182 | 1527095 | ព្រៃទើបកាប់រាន |
| 5 | 749118 | 1527074 | ព្រៃទើបកាប់រាន |
| 6 | 748897 | 1526995 | ព្រៃទើបកាប់រាន |
| 7 | 750500 | 1529500 | ព្រៃទើបកាប់រាន |
| 8 | 750897 | 1530755 | ចំការស្វាយចន្ទី |
| 9 | 752576 | 1532909 | ចំការស្វាយចន្ទី |
| 10 | 753358 | 1532640 | ចំការស្វាយចន្ទី |
| 11 | 753751 | 1532292 | ចំការស្វាយចន្ទី |
| 12 | 753829 | 1532217 | ចំការស្វាយចន្ទី |
| 13 | 750018 | 1527827 | ដីភូមិ |
| 14 | 750301 | 1527917 | ដីភូមិ |
| 15 | 750061 | 1527638 | ព្រៃទើបកាប់រាន |
| 16 | 750650 | 1527878 | ព្រៃទើបកាប់រាន |
| 17 | 750727 | 1528089 | បង្គោលព្រំ.ស.ក |
| 18 | 750894 | 1528123 | បង្គោលព្រំ.ស.ក |
| 19 | 751050 | 1528755 | ព្រៃទើបកាប់រាន |
| 20 | 751112 | 1528441 | ព្រៃទើបកាប់រាន |
| 21 | 750307 | 1530257 | ព្រៃទើបកាប់រាន |
| 22 | 750520 | 1529905 | ព្រៃទើបកាប់រាន |
| 23 | 750331 | 1530059 | ព្រៃទើបកាប់រាន |
| 24 | 750698 | 1530013 | ចំការកៅស៊ូ |
| 25 | 750750 | 1530407 | ចំការកៅស៊ូ |
| 26 | 751214 | 1530118 | ចំការកៅស៊ូ |
| 27 | 751102 | 1529818 | ចំការកៅស៊ូ |
| 28 | 751168 | 1529574 | ចំការកៅស៊ូ |
| 29 | 750753 | 1529536 | ចំការកៅស៊ូ |
| 30 | 751008 | 1529082 | ចំការកៅស៊ូ |
| 31 | 750464 | 1530669 | ចំការស្វាយចន្ទី |
| 32 | 750030 | 1529909 | ផ្ទះនិងចំការជនជាតិ |
| 33 | 750134 | 1529979 | ផ្ទះនិងចំការជនជាតិ |
| 34 | 750080 | 1529994 | ផ្ទះនិងចំការជនជាតិ |
| 35 | 751051 | 1530457 | ចំការស្វាយចន្ទី |
| 36 | 751297 | 1529606 | ចំការស្វាយចន្ទី |
| 37 | 751275 | 1529920 | ចំការស្វាយចន្ទី |
| 38 | 751350 | 1528514 | ព្រៃទើបកាប់រាន |
| 39 | 749996 | 1530532 | ព្រៃទើបកាប់រាន |
| 40 | 750118 | 1530541 | ព្រៃទើបកាប់រាន |

លេខៈ ៤៧៦ ស.ជ.

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តរតនគិរី និង សំរេច

អណ្តូងមាស ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១០

អភិបាលស្រុក

ឡិច ជាំង

លេខៈ ៧១៥ ស.ជ.ខ

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តរតនគិរី និង សំរេច

រតនគិរី ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១០

ប្រធានមន្ទីរកសិកម្មខេត្ត

សយ សុវណា

លេខៈ ៤២/១០

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តរតនគិរី និង សំរេច

រតនគិរី ថ្ងៃទី ខែ វិច្ឆិកា ឆ្នាំ ២០១០

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

ធីប ស៊ីណាត

លេខៈ ១៣០៤/១០

បានឃើញ និង ឯកភាព

គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មេត្តាពិនិត្យ និង សំរេច

រតនគិរី ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១០

អភិបាលខេត្ត

ផេង សាខុន